ការិយាល័យកណ្តាល

អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

# កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ទទួលជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ (“កិច្ចប្រជុំ”) តាមរយៈ **អ៊ីម៉ែល** ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤** ចាប់ពីម៉ោង **១៤:០០ រសៀល** ដល់ម៉ោង **១៦:០០ រសៀល** នូវរបៀបវារៈដូចខាងក្រោម៖

១. អនុម័ត និងតែងតាំង **លោក កាយ ឡូត** ជាអភិបាលឯករាជ្យ ធនាគារ អេស៊ីលីដា។

២ . អនុម័តការធ្វើវិសោធនកម្ម ឧបសម្ព័ន្ធ១ (“សមាសភាពក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ភីអិលស៊ី”) នៃលក្ខន្តិកៈ ធនាគារ អេស៊ីលីដា។

ភាគហ៊ុនិក ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក**នៅកាលបរិច្ឆេទកំណត់ទុកថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤** នឹងទទួលបាននូវលិខិតអញ្ជើញ ឯកសារគាំទ្រ សេចក្តីណែនាំអំពីការបោះឆ្នោតតាមប្រព័ន្ធ e-Voting លិខិតប្រគល់សិទ្ធិ និង QR Code សម្រាប់ការបោះឆ្នោត ដែលធនាគារ អេស៊ីលីដា នឹងផ្ញើជូនតាមរយៈអ៊ីម៉ែល។ ក្នុងករណីដែលភាគហ៊ុនិកណាម្នាក់ ពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទកំណត់ អាចផ្តល់សិទ្ធិប្រទានទៅឱ្យអ្នកតំណាងណាម្នាក់ ដើម្បីចូលរួម និងបោះឆ្នោតជំនួស។ ភាគហ៊ុនិក ឬអ្នកទទួលសិទ្ធិត្រូវផ្ញើលិខិតប្រគល់សិទ្ធិច្បាប់ដើមមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា **យ៉ាងយូរត្រឹមថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។**

ដំណើរការនៃការបោះឆ្នោតមានដូចខាងក្រោម៖

១. ធនាគារ អេស៊ីលីដា នឹងផ្ញើ QR Code សម្រាប់បោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗតាមរយៈអ៊ីម៉ែល ចាប់ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤ ម៉ោង ១២:០០ ថ្ងៃត្រង់ (ម៉ោងនៅភ្នំពេញ)។

២. ភាគហ៊ុនិកម្នាក់ៗត្រូវបោះឆ្នោតនៅ**ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៤** ក្នុងចន្លោះពេលណាមួយ ចាប់ពីម៉ោង **១៤:០០ រសៀល ដល់ម៉ោង ១៦:០០ រសៀល** (ម៉ោងនៅភ្នំពេញ) ដោយបើកកាមេរ៉ាទូរស័ព្ទដៃ ឬ Tablet របស់លោក/អ្នក រួចស្កេន QR Code សម្រាប់បោះឆ្នោត (សូមមើលសេចក្តីណែនាំអំពីការបោះឆ្នោតតាមប្រព័ន្ធ e-voting ដែលនឹងផ្ញើជូនជាមួយ QR Code)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកិច្ចប្រជុំនេះតាមរយៈអ៊ីម៉ែលតាមកាលបរិច្ឆេទដែលបានកំណត់ ដោយសេចក្តីអនុគ្រោះ។ ប្រសិនបើលោក/អ្នកមានតម្រូវការ ឬសំណួរផ្សេងៗ សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (ភ្នាក់ងារ RTP) របស់ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

- **លោក ហួត សុភី** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ➢ ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - ➢ អ៊ីម៉ែល: huot.sophy@acledabank.com.kh

- **លោក កែន រិទ្ធពុទ្ធា** អ្នកឯកទេសបឋមប្រតិបត្តិការ RTP
  - ➢ ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - ➢ អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** អ្នកឯកទេសបឋមប្រតិបត្តិការ RTP
  - ➢ ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - ➢ អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៤

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**